ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៥ សហវ.ទាន

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៥

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តនីតិវិធីកាត់ទុកប្រាក់ពន្ធនៃកិច្ចលទ្ធកម្ម

អនុលោមតាមខ្លឹមសារប្រកាសលេខ ១៦១ សហវ. ពដ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០០៥ ស្តីពីកាតព្វកិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម និង ដើម្បីសំរួលដល់កិច្ចបញ្ជីការបង់ប្រាក់ចូលថវិការដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំដូចខាងក្រោម:

១- ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនិងមធ្យម និងសាខាពន្ធដារគ្រប់ខេត្ត-ក្រុង ត្រូវស្នើសុំបើកគណនីចំណូលបណ្តោះអាសន្នពន្ធដារ នៅធនាគារជាតិ គណនីលេខ ៤៧១.១ និង នៅរតនាគារខេត្ត-ក្រុង គណនីលេខ ៤៧១.២ ។

២- សំណុំឯកសារស្នើសុំទូទាត់ថ្លៃទំនិញឬសេវា ត្រូវមានភ្ជាប់ជាមួយនូវប័ណ្ណប៉ាតង់ ។ ការកាត់ទុកប្រាក់ពន្ធពីអាណត្តិបើកប្រាក់ រតនាគារត្រូវធ្វើការកាត់ទុកប្រាក់ពន្ធដោយផ្អែកលើមូលដ្ឋានប័ណ្ណប៉ាតង់ ដើម្បីកំណត់ការកាត់យកប្រាក់ពន្ធ ។ បើប័ណ្ណប៉ាតង់ដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ គឺជាប័ណ្ណប៉ាតង់របស់អ្នកជាប់ពន្ធតាមរបបពិត តែបើនៅក្នុងប័ណ្ណប៉ាតង់ពុំមានលេខអត្តសញ្ញាណកម្មសារពើពន្ធនោះទេ គឺជាប័ណ្ណប៉ាតង់របស់អ្នកជាប់ពន្ធតាមរបបម៉ៅការ ។

៣- ប្រាក់ពន្ធដែលបានកាត់ទុកពីអាណត្តិបើកប្រាក់ដោយរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង ត្រូវផ្ទេរចូលក្នុងគណនីចំណូលបណ្តោះអាសន្នពន្ធដារ (៤៧១.១) ឬ (៤៧១.២) រក្សាទុកជូនការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង និងអ្នកជាប់ពន្ធ ។ រតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង ត្រូវធ្វើប្រកាសឥណទានស្តីពីចំនួនប្រាក់ពន្ធទាំងនោះជូនទៅការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង ។

៤- ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនិងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង ពេលទទួលបានប្រកាសឥណទានពីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុងរួចហើយ ត្រូវធ្វើការពិនិត្យមើលដើម្បីឱ្យដឹងថាទឹកប្រាក់ពន្ធរបស់អ្នកជាប់ពន្ធស្ថិតនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន ឬជារបស់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេង ។ បើទឹកប្រាក់ពន្ធទាំងនេះជារបស់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ការិយាល័យ ឬរបស់សាខាពន្ធដារខេត្ត-ក្រុងខ្លួន ការិយាល័យ ឬសាខាពន្ធដារខេត្ត-ក្រុងនោះត្រូវផ្តល់បង្កាន់ដៃពន្ធជូនទៅអ្នកជាប់ពន្ធ និងត្រូវធ្វើសលាកប័ត្របង់ប្រាក់ចំណូលចូលថវិការដ្ឋ (គណនីលេខ ៩០០) ។ បើទឹកប្រាក់ពន្ធទាំងនេះជារបស់អ្នកជាប់ពន្ធដែលមិនស្ថិតនៅក្នុងការគ្រប់គ្រងរបស់ការិយាល័យ ឬរបស់សាខាពន្ធដារខេត្ត-ក្រុងខ្លួនទេនោះ ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យមនៅភ្នំពេញ ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយទៅរតនាគារជាតិ សាខាពន្ធដារ

ខេត្ត-ក្រុង ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយទៅរតនាគារខេត្ត-ក្រុង ដើម្បីសុំផ្ទេរប្រាក់ពន្ធនោះទៅឱ្យការិយាល័យ ឬសាខាពន្ធដារខេត្ត-ក្រុង ដែលគ្រប់គ្រងអ្នកជាប់ពន្ធនោះ ។

៥- ករណីផ្ទេរប្រាក់ពន្ធពីថ្នាក់កណ្តាលទៅខេត្ត-ក្រុង ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយជូនទៅរតនាគារជាតិ ។ រតនាគារជាតិត្រូវប្រគល់ប័ណ្ណផ្ទេរភារៈចំណាយមួយច្បាប់ ព្រមទាំងប័ណ្ណផ្ទេរភារៈចំណាយ និងប្រកាសឥណទានដែលដាក់ក្នុងស្រោមសំបុត្របិទជិតទៅឱ្យការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ដែលជាសាមីអ្នកស្នើសុំ ។ ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ត្រូវយកឯកសារក្នុងស្រោមសំបុត្រទៅប្រគល់ជូនរតនាគារខេត្ត-ក្រុង ដែលពាក់ព័ន្ធ ដើម្បីកត់ត្រាទៅក្នុងគណនីចំណូលបណ្តោះអាសន្នរបស់សាខាពន្ធដារ (គណនីលេខ ៤៧១) ដែលជាអ្នកទទួលប្រាក់ពន្ធ ហើយជូនដំណឹងទៅសាខាពន្ធដារនោះ ដើម្បីរៀបចំសលាកប័ត្របង់ចំណូលថវិកា (គណនីលេខ ៩០០) ។

៦- ករណីផ្ទេរប្រាក់ពន្ធពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយផ្សេងទៀត សាខាពន្ធដារខេត្ត-ក្រុង ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយស្នើសុំផ្ទេរប្រាក់ពន្ធជូនទៅរតនាគារខេត្ត-ក្រុងសាមី ។ រតនាគារខេត្ត-ក្រុង ត្រូវប្រគល់ប័ណ្ណផ្ទេរភារៈចំណាយមួយច្បាប់ ព្រមទាំងប័ណ្ណផ្ទេរភារៈចំណាយនិងប្រកាសឥណទានដែលដាក់ក្នុងស្រោមសំបុត្របិទជិតទៅឱ្យសាខាពន្ធដារដែលជាអ្នកស្នើសុំផ្ទេរ ។ សាខាពន្ធដារដែលជាអ្នកស្នើសុំ ត្រូវបញ្ជូនឯកសារនៅក្នុងស្រោមសំបុត្រមករតនាគារជាតិដើម្បីចុះបញ្ជី ។ រតនាគារជាតិត្រូវរៀបចំប្រកាសឥណទានមួយថ្មីដាក់ក្នុងស្រោមសំបុត្រ រួចប្រគល់ជូនទៅសាខាពន្ធដារដែលត្រូវទទួលប្រាក់ពន្ធតាមរយៈនាយកដ្ឋានពន្ធដារ ។ ក្រោយពីបានទទួលប័ណ្ណផ្ទេរភារៈចំណាយ និងប្រកាសឥណទាន រតនាគារខេត្ត-ក្រុង ត្រូវកត់ត្រាទៅក្នុងគណនីចំណូលបណ្តោះអាសន្នរបស់សាខាពន្ធដារ (គណនីលេខ ៤៧១) ដែលជាអ្នកទទួលប្រាក់ពន្ធ ហើយជូនដំណឹងទៅសាខាពន្ធដារនោះ ដើម្បីរៀបចំសលាកប័ត្របង់ចំណូលថវិកា (គណនីលេខ ៩០០) ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានពន្ធដារ ចាត់ចែងអនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

ចំលងជូន :

- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- រតនាគារខេត្ត-ក្រុង
- សាខាពន្ធដារខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ